# វេទិកាកម្រិតខ្ពស់លើកទី ៣ ស្តីពីប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការ

***THIRD HIGH LEVEL FORUM ON AID EFFECTIVENESS***

ថ្ងៃទី ២-៤ ខែកញ្ញា ឆ្នាំ ២០០៨ ទីក្រុងអាក្រា ប្រទេសហ្កាណា

## ផែនការសកម្មភាពអាក្រា

ACCRA AGENDA FOR ACTION

*រដ្ឋមន្ត្រីនៃប្រទេសកំពុងអភិវឌ្ឍន៍ និងប្រទេសផ្តល់ហិរញ្ញប្បទានដែលទទួលបន្ទុកការអភិវឌ្ឍន៍ និងប្រធានស្ថាប័នអភិវឌ្ឍន៍ពហុភាគីនិងទ្វេភាគី បានអនុម័តសេចក្តីថ្លែងការណ៍ដូចខាងក្រោម នៅទីក្រុងអាក្រា ប្រទេសហ្កាណា នាថ្ងៃទី ៤ ខែកញ្ញា ឆ្នាំ ២០០៨ ដើម្បីពន្លឿន និងធ្វើឱ្យស៊ីជម្រៅ ការអនុវត្តន៍សេចក្តីថ្លែងការណ៍ទីក្រុងប៉ារីសស្តីពីប្រសិទ្ធិភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការ (ថ្ងៃទី២ ខែមិនា ឆ្នាំ ២០០៥)*

***នេះជាកាលានុវត្តភាពមួយ***

១- យើងបានប្តេជ្ញាថានឹងលុបបំបាត់ភាពក្រីក្រ និងជម្រុញឱ្យមានសន្តិភាព និងភាពរុងរឿង តាមរយៈការកសាងនូវភាពជាដៃគូមួយរឹងមាំ និងដែលមានប្រសិទ្ធភាព សម្រាប់ជួយដល់ប្រទេសកំពុងអភិវឌ្ឍន៍ ឱ្យសម្រេចនូវគោលដៅអភិវឌ្ឍន៍ ។

២- យើងសម្រេចបាននូវវឌ្ឍនភាពក្នុងរយៈពេលកន្លងមក ។ មុននេះ ១៥ ឆ្នាំ មានមនុស្សពីរនាក់ក្នុងចំណោមមនុស្សប្រាំនាក់រស់នៅក្នុងភាពក្រីក្របំផុត ។ បច្ចុប្បន្ន មានមនុស្សមួយនាក់ក្នុងចំណោមប្រាំនាក់រស់នៅក្នុងភាពក្រីក្របំផុត ។ ប៉ុន្តែមានមនុស្ស ១.៤០០ លាននាក់ ដែលភាគច្រើនជាក្មេងស្រី និងស្ត្រី នៅបន្តរស់នៅក្នុងភាពក្រីក្របំផុតនៅឡើយ រីឯទឹកស្អាតសម្រាប់ទទួលទាន និងការថែទាំសុខភាព នៅតែជាបញ្ហាចម្បងនៅក្នុងប្រទេសជាច្រើននៅលើពិភពលោក ។ បន្ថែមពីលើនេះទៀត បញ្ហាប្រឈមដែលមានចរិតសកលថ្មីៗ ដូចជាការឡើងថ្លៃម្ហូបអាហារ និងប្រេងឥន្ធនៈ និងការប្រែប្រួលអាកាសធាតុ បានក្លាយទៅជាការគំរាមកំហែងដល់សមិទ្ធផលដែលយើងសម្រេចបានជាលទ្ធផលនៃការកាត់បន្ថយភាពក្រីក្រនៅក្នុងប្រទេសជាច្រើន ។

៣- យើងត្រូវសម្រេចឱ្យបាននូវលទ្ធផលច្រើនជាងនេះថែមទៀត ប្រសិនបើប្រទេសទាំងអស់ចង់ទទួលបានជោគជ័យសម្រេចនូវគោលដៅអភិវឌ្ឍន៍សហសវត្សរ៍ ។ ហិរញ្ញប្បទានសហប្រតិបត្តិការគ្រាន់តែជាធាតុផ្សំមួយនៃការអភិវឌ្ឍន៍ប៉ុណ្ណោះ ។ លទ្ធិប្រជាធិបតេយ្យ កំណើនសេដ្ឋកិច្ច ការរីកចម្រើនផ្នែកសង្គមកិច្ច និងការយកចិត្តទុកដាក់ចំពោះបរិស្ថាន គឺជាក្បាលម៉ាស៊ីនដ៏សំខាន់សម្រាប់ការអភិវឌ្ឍន៍នៅក្នុងបណ្តាប្រទេសទាំងអស់ ។ ការដោះស្រាយបញ្ហាវិសមភាពនៃចំណូលនិងឱកាស នៅក្នុងប្រទេសនិមួយៗ និងរវាងបណ្តាប្រទេសនានា គឺជាកត្តាសំខាន់មួយសម្រាប់វិបុលភាពសកលលោក ។ សមភាពយែនឌ័រ ការគោរពសិទ្ធិមនុស្ស និងនិរន្តភាពបរិស្ថាន ជាមូលដ្ឋានគ្រឹះសម្រាប់ធានាឱ្យបាននូវការផ្លាស់ប្តូរប្រសើរឡើងនូវជីវភាពរស់នៅ និងការប្រើប្រាស់អស់នូវសក្តានុពលរបស់ស្ត្រី បុរស និងកុមារដែលរស់ក្នុងភាពក្រីក្រ ។ ហេតុដូចនេះហើយ ជាការចាំបាច់ដែលគោលនយោបាយរបស់យើងទាំងអស់គ្នា សម្រាប់ដោះស្រាយបញ្ហាទាំងនេះ ត្រូវតែមានលក្ខណៈជាប្រព័ន្ធ និងមានសង្គតិភាពច្រើនជាងមុន ។

៤- នៅក្នុងឆ្នាំ ២០០៨ មានសន្និសីទអន្តរជាតិចំនួនបី ដែលនឹងជួយឱ្យយើង អាចពន្លឿនល្បឿននៃការផ្លាស់ប្តូរបន្ថែមទៀត នោះគឺវេទិកាកម្រិតខ្ពស់ស្តីពីប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការ ទីក្រុង ACCRA វេទិកាកម្រិតខ្ពស់របស់អង្គការសហប្រជាជាតិស្តីពីគោលដៅអភិវឌ្ឍន៍សហសវត្សរ៍ នៅទីក្រុងNEW YORK និងកិច្ចប្រជុំតាមដានស្តីពីហិរញ្ញប្បទានសម្រាប់ការអភិវឌ្ឍន៍ នៅទីក្រុង DOHA ។ ថ្ងៃនេះនៅទីក្រុង ACCRA យើងកំពុងត្រួសត្រាយផ្លូវ ផ្សារភ្ជាប់ដោយគោលដៅរួមមួយ

នោះគឺ បំប្លែងនូវសក្តានុពលទាំងអស់របស់ហិរញ្ញប្បទានសហប្រតិបត្តិការ ដើម្បីសម្រេចលទ្ធផលអភិវឌ្ឍន៍មួយដែលមានចីរភាព ។

### *វឌ្ឍនភាពដែលយើងសម្រេចបាននៅមិនទាន់គ្រប់គ្រាន់នៅឡើយ*

៥- ដោយដកស្រង់យកនូវមេរៀននៃភាពជោគជ័យនិងបរាជ័យនៅក្នុងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងមានមូលដ្ឋានលើសេចក្តីប្រកាសទីក្រុងរ៉ូមស្តីពីសុខដុមនីយកម្ម ឆ្នាំ២០០៣ យើងបានឯកភាព នៅក្នុងខែមិនា ឆ្នាំ២០០៥ ធ្វើការកែទំរង់មួយប្រកបដោយមហិច្ឆតា នោះគឺការអនុម័តសេចក្តីថ្លែងការណ៍ទីក្រុងប៉ារីសស្តីពីប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការ ។ នៅក្នុងសេចក្តីថ្លែងការណ៍ទីក្រុងប៉ារីស យើងបានឯកភាពនឹងកសាងនូវភាពជាដៃគូមួយដែលពិតប្រាកដ ដែលក្នុងនោះ ប្រទេសកំពុងអភិវឌ្ឍន៍មានភារៈដឹកនាំដោយផ្ទាល់នូវដំណើរការនៃការអភិវឌ្ឍន៍របស់ខ្លួន ។ យើងក៏បានឯកភាពផងដែរ ថានឹងទទួលខុសត្រូវចំពោះគ្នាទៅវិញទៅមក នៅលើលទ្ធផលនៃការអភិវឌ្ឍន៍ ។ បីឆ្នាំកន្លះបន្ទាប់មក យើងជួបជុំគ្នានៅទីនេះ ទីក្រុង ACCRA ដើម្បីពិនិត្យមើលពីវឌ្ឍនភាព និងដោះស្រាយបញ្ហាប្រឈមដែលយើងជួបប្រទះ ។

៦- មានភស្តុតាងជាច្រើនបានបង្ហាញថា យើងសម្រេចបាននូវវឌ្ឍនភាព ក៏ប៉ុន្តែនៅមិនទាន់គ្រប់គ្រាន់នោះទេ ។ ការវាយតម្លៃនាពេលថ្មីៗបង្ហាញថា សេចក្តីថ្លែងការណ៍ទីក្រុងប៉ារីសបានផ្តល់ជាកម្លាំងដ៏មានឥទ្ធិពលមួយ ជម្រុញឱ្យមានការផ្លាស់ប្តូរបែបបទនៃកិច្ចសហការជាក់ស្តែង រវាងប្រទេសកំពុងអភិវឌ្ឍន៍ និងប្រទេស/ ស្ថាប័នផ្តល់ហិរញ្ញប្បទាន ។ ដូចលទ្ធផលនៃការអង្កេតតាមដានឆ្នាំ ២០០៨ មានប្រទេសកំពុងអភិវឌ្ឍន៍ជាច្រើនបានធ្វើឱ្យប្រសើរឡើងនូវការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។ ទន្ទឹមនេះ ការសម្របសម្រួលការផ្តល់ហិរញ្ញប្បទានក៏មានភាពប្រសើរឡើង ។ ប៉ុន្តែវឌ្ឍនភាពមានល្បឿនយឺតមែនទែន ។ បើគ្មានការកែទម្រង់បន្ថែម និងការអនុវត្តន៍ឱ្យបានឆាប់រហ័សថែមទៀតទេ យើងនឹងមិនអាចសម្រេចបាននូវការប្តេជ្ញាដែលយើងបានសន្យា សម្រាប់ឆ្នាំ ២០១០ និងសម្រេចនូវគោលដៅក្នុងការលើកកំពស់ប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការនោះទេ ។

### *យើងនឹងពន្លឿនឱ្យមានវឌ្ឍនភាពបន្ថែមទៀត*

៧- ភស្តុតាងជាច្រើនបានបង្ហាញថា យើងត្រូវដោះស្រាយបញ្ហាប្រឈមចម្បងបី ដើម្បីពន្លឿនវឌ្ឍនភាពនៃការលើកកំពស់ប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការ ÷

៨- *ភាពជាម្ចាស់គឺជាគន្លឹះ* ។ រដ្ឋាភិបាលនៃប្រទេសកំពុងអភិវឌ្ឍន៍នឹងពង្រឹងនូវភាពជាអ្នកដឹកនាំលើគោលនយោបាយអភិវឌ្ឍន៍ និងជម្រុញឱ្យមានការចូលរួមពីស្ថាប័ននីតិបញ្ញត្តិ និងប្រជាពលរដ្ឋ ក្នុងដំណើរការរៀបចំគោលនយោបាយទាំងនោះ ។ ប្រទេស/ ស្ថាប័នផ្តល់ហិរញ្ញប្បទាននឹងគោរពនូវអាទិភាពអភិវឌ្ឍន៍របស់ប្រទេសជាដៃគូ គាំទ្រការបណ្តុះបណ្តាលធនធានមនុស្ស និងស្ថាប័ន បង្កើនការប្រើប្រាស់នូវប្រព័ន្ធនីតិវិធីជាតិរបស់ប្រទេសជាដៃគូសម្រាប់ផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការ និងបង្កើនភាពអាចទស្សន៍ទាយបាននៃលំហូរហិរញ្ញប្បទាន ។

៩- *កសាងភាពជាដៃគូមួយដែលមានប្រសិទ្ធិភាព និងមានការចូលរួម* ។ ក្នុងរយៈពេលកន្លងមក កំណើននៃតួអង្គអភិវឌ្ឍន៍ ដែលរួមមានប្រទេសដែលមានចំណូលមធ្យម អង្គការមូលនិធិពិភពលោក វិស័យឯកជន និងអង្គការសង្គមស៊ីវិលបានផ្តល់ជាការរួមចំណែក និងនាំមកនូវបទពិសោធន៍ផ្សេងៗសម្រាប់ចែករំលែក ។ ស្ថានភាពដូចនេះ ក៏បង្កើតឱ្យមានបញ្ហាប្រឈមផ្នែកគ្រប់គ្រង និងសម្របសម្រួលផងដែរ ។ ហេតុដូចនេះហើយ ដៃគូអភិវឌ្ឍន៍ទាំងអស់ នឹងសហការក្នុងភាពជាដៃគូ ដើម្បីធ្វើឱ្យកិច្ចប្រឹងប្រែងរបស់យើងចូលរួមដល់ការកាត់បន្ថយភាពក្រីក្រ ។

១០- *ការផ្តោតលើលទ្ធផលអភិវឌ្ឍន៍ និងទទួលខុសត្រូវចំពោះការសម្រេចនូវលទ្ធផល ជាមូលដ្ឋាននៃកិច្ចប្រឹងប្រែងរួមរបស់យើង* ។ ជាងពេលណាៗទាំងអស់ ប្រជាពលរដ្ឋ និងអ្នកបង់ពន្ធនៃប្រទេសទាំងអស់ កំពុងទន្ទឹងរង់ចាំមើលលទ្ធផល

ជាក់ស្តែងនៃការប្រឹងប្រែងអភិឌ្ឍន៍ ។ យើងនឹងបង្ហាញឱ្យឃើញថាសកម្មភាពរបស់យើងនឹងមានឥទ្ធិពលជាវិជ្ជមានទៅលើជីវភាពរស់នៅរបស់ប្រជាជន ។ យើងនឹងទទួលខុសត្រូវចំពោះគ្នាទៅវិញទៅមក និងនៅចំពោះមុខស្ថាប័ននីតិបញ្ញត្តិ និងរដ្ឋាភិបាលរបស់យើងនៅលើលទ្ធផលទាំងអស់នេះ ។

១១- ប្រសិនបើបញ្ហាប្រឈមទាំងនេះមិនត្រូវបានដោះស្រាយ យើងនឹងមិនអាចសម្រេចតាមការប្តេជ្ញារបស់យើង និងបាត់បង់នូវឱកាសសម្រាប់លើកកំពស់កម្រិតជីវភាពរបស់ប្រជាជនភាគច្រើនដែលងាយទទួលរងគ្រោះនៅក្នុងពិភពលោក ។ ហេតុនេះ យើងសូមអះអាងបញ្ជាក់សាជាថ្មីឡើងវិញ នូវការប្តេជ្ញាដែលយើងបានធ្វើនៅក្នុងសេចក្តីថ្លែងការណ៍ទីក្រុងប៉ារីស ។ តាមរយៈផែនការសកម្មភាពទីក្រុងអាក្រា យើងបានឯកភាពយល់ព្រមលើសកម្មភាពជាក់ស្តែង និងដែលអាចត្រួតពិនិត្យបានដើម្បីពន្លឿនវឌ្ឍនភាពក្នុងការឈានទៅសម្រេចនូវការប្តេជ្ញាទាំងអស់នៅត្រឹមឆ្នាំ ២០១០ ។ យើងក៏ប្តេជ្ញាផងដែរ ក្នុងការបន្តកិច្ចប្រឹងប្រែងតាមដាន និងវាយតម្លៃ សម្រាប់វាស់ស្ទង់ការអនុវត្តន៍ការប្តេជ្ញាដែលយើងបានព្រមព្រៀងនៅក្នុងសេចក្តីថ្លែងការណ៍ទីក្រុងប៉ារីស និងនៅក្នុងផែនការសកម្មភាពទីក្រុងអាក្រា និងកំណត់ពីប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការ ក្នុងការសម្រេចបាននូវលទ្ធផលអភិវឌ្ឍន៍ ។

## ពង្រឹងភាពជាម្ចាស់លើការអភិវឌ្ឍន៍

១២- ប្រទេសកំពុងអភិវឌ្ឍន៍ជាអ្នកកំណត់ និងអនុវត្តន៍គោលនយោបាយអភិវឌ្ឍន៍ ដើម្បីសម្រេចគោលដៅអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គម និងបរិស្ថាន ។ ដូចដែលបានព្រមព្រៀងនៅក្នុងសេចក្តីថ្លែងការណ៍ទីក្រុងប៉ារីស នេះគឺជាអាទិភាពទីមួយរបស់យើងទាំងអស់គ្នា ។ ថ្ងៃនេះយើងនឹងកំណត់ជំហានបន្ថែមទៀត ដើម្បីប្រែក្លាយការប្តេជ្ញានេះឱ្យក្លាយជាការពិត ។

### *យើងនឹងពង្រីកការចូលរួមក្នុងការពិភាក្សាអំពីគោលនយោបាយនៃការអភិវឌ្ឍន៍នៅកម្រិតប្រទេស*

១៣- យើងនឹងចូលរួមក្នុងការពិភាក្សាអំពីគោលនយោបាយនៃការអភិវឌ្ឍន៍មួយ ដែលបើកចំហ និងទូលំទូលាយ ។ យើងទទួលស្គាល់នូវតួនាទី និងការទទួលខុសត្រូវដ៏មានសារៈសំខាន់នៃស្ថាប័នសភា ក្នុងការធានាភាពជាម្ចាស់របស់ប្រទេសក្នុងការអភិវឌ្ឍន៍ ។ ដើម្បីសម្រេចនូវគោលដៅនេះ យើងនឹងអនុវត្តសកម្មភាពខាងក្រោម ÷

ក- រដ្ឋាភិបាលនៃប្រទេសកំពុងអភិវឌ្ឍន៍នឹងសហការជិតស្និទជាមួយស្ថាប័នសភា និងអាជ្ញាធរមូលដ្ឋានក្នុងការរៀបចំ ការអនុវត្តន៍ និងតាមដានការអនុវត្តន៍គោលនយោបាយ និងផែនការអភិវឌ្ឍន៍ ។ ព្រមជាមួយនេះនឹងសហការជាមួយអង្គការសង្គមស៊ីវិលផងដែរ ។

ខ- ប្រទេស/ស្ថាប័នផ្តល់ហិរញ្ញប្បទាននឹងផ្តល់ការគាំទ្រដល់កិច្ចប្រឹងប្រែងកសាងសមត្ថភាព របស់តួអង្គអភិវឌ្ឍន៍ទាំងអស់ ដែលមានដូចជាស្ថាប័នសភា រដ្ឋបាលថ្នាក់ជាតិ និងមូលដ្ឋាន អង្គការសង្គមស៊ីវិល វិទ្យាស្ថានស្រាវជ្រាវ ប្រព័ន្ធផ្សព្វផ្សាយ និងវិស័យឯកជន ដើម្បីឱ្យពួកគេអាចមានតួនាទីសកម្ម នៅក្នុងការពិភាក្សាលើគោលនយោបាយអភិវឌ្ឍន៍ និងអំពីតួនាទីនៃហិរញ្ញប្បទានសហប្រតិបត្តិការក្នុងការរួមចំណែក សម្រេចគោលដៅអភិឌ្ឍន៍របស់ប្រទេស ។

គ- ប្រទេសកំពុងអភិវឌ្ឍន៍ និងប្រទេស/ស្ថាប័នផ្តល់ហិរញ្ញប្បទាន នឹងធានាថាការរៀបចំ និងអនុវត្តគោលនយោបាយ និងកម្មវិធីអភិវឌ្ឍន៍របស់ពួកគេរៀងៗខ្លួន នឹងមានសង្គតិភាពជាមួយការប្តេជ្ញាដែលបានធ្វើជាអន្តរជាតិស្តីពីសមភាពយេនឌ័រ សិទ្ធិមនុស្ស និងនិរន្តរភាពនៃជនពិការ និងបរិស្ថាន ។

### *ប្រទេសកំពុងអភិវឌ្ឍន៍នឹងពង្រឹងសមត្ថភាពក្នុងការដឹកនាំ និងគ្រប់គ្រងការអភិវឌ្ឍន៍*

១៤- កង្វះសមត្ថភាព- - ភាពរឹងមាំនៃស្ថាប័ន ប្រពន្ធ័នីតិវិធី និងជំនាញក្នុងស្រុក- - ប្រទេសកំពុងអភិវឌ្ឍន៍មិនមានលទ្ធភាពគ្រប់គ្រាន់សម្រាប់ធ្វើជាម្ចាស់ និងគ្រប់គ្រងដំណើរការអភិវឌ្ឍន៍របស់ជាតិបានទេ ។ ដូចយើងបានឯកភាពនៅក្នុងសេចក្តីថ្លែងការណ៍ទីក្រុងប៉ារីស ការអភិវឌ្ឍន៍សមត្ថភាពគឺជាភារៈទទួលខុសត្រូវរបស់ប្រទេសកំពុងអភិវឌ្ឍន៍រីឯប្រទេស/ ស្ថាប័នផ្តល់ហិរញ្ញប្បទានមានតួនាទីផ្តល់ការគាំទ្រ ។ យើងបានឯកភាពផងដែរថាកិច្ចសហប្រតិបត្តិការបច្ចេកទេស ជាឧបករណ៍មួយក្នុងចំណោមឧបករណ៍ដទៃទៀត សម្រាប់អភិវឌ្ឍសមត្ថភាព ។ ជារួម ប្រទេសកំពុងអភិវឌ្ឍន៍ និងប្រទេស/ ស្ថាប័នផ្តល់ហិរញ្ញប្បទាននឹងអនុវត្តនូវសកម្មភាពដូចខាងក្រោមសម្រាប់ការអភិវឌ្ឍន៍សមត្ថភាព ÷

ក- ប្រទេសកំពុងអភិវឌ្ឍន៍នឹងកំណត់ ជាលក្ខណៈជាប្រព័ន្ធ នូវតម្រូវការនៃការពង្រឹងសមត្ថភាព ក្នុងការផ្តល់សេវានៅគ្រប់កម្រិត នៅថ្នាក់ជាតិ ថ្នាក់មូលដ្ឋាន នៅតាមវិស័យ និងនៅតាមបញ្ហា ព្រមទាំងរៀបចំជាយុទ្ធសាស្ត្រដើម្បីឆ្លើយតបនឹងតម្រូវការទាំងនោះ ។ ប្រទេស/ ស្ថាប័នផ្តល់ហិរញ្ញប្បទាននឹងខិតខំពង្រឹងសមត្ថភាព និងជំនាញដើម្បីអាចឆ្លើយតបបានកាន់តែប្រសើរទៅនឹងតម្រូវការរបស់ប្រទេសកំពុងអភិវឌ្ឍន៍ ។

ខ- ការគាំទ្ររបស់ប្រទេស/ ស្ថាប័នផ្តល់ហិរញ្ញប្បទានទៅលើការអភិវឌ្ឍន៍សមត្ថភាព ត្រូវតែផ្អែកលើតម្រូវការ និងត្រូវតែផ្តល់ការគាំទ្រដល់ភាពជាម្ចាស់របស់ប្រទេសទទួលហិរញ្ញប្បទាន ។ ក្នុងន័យនេះ ប្រទេសកំពុងអភិវឌ្ឍន៍ និងប្រទេស/ ស្ថាប័នផ្តល់ហិរញ្ញប្បទាន នឹង (១) ធ្វើការជ្រើសរើស និងគ្រប់គ្រងកិច្ចសហប្រតិបត្តិការបច្ចេកទេសរួមគ្នា និង (២) ខិតខំជម្រុញឱ្យមានកិច្ចសហប្រតិបត្តិការបច្ចេកទេសដែលប្រើប្រាស់ធនធានក្នុងស្រុក និងនៅក្នុងតំបន់ ដោយរួមទាំងកិច្ចសហប្រតិបត្តិការត្បូង- ត្បូង ។

គ- ប្រទេសកំពុងអភិវឌ្ឍន៍ និងប្រទេស/ ស្ថាប័នផ្តល់ហិរញ្ញប្បទាននឹងសហការគ្នានៅគ្រប់កម្រិត ដើម្បីជម្រុញឱ្យមានការផ្លាស់ប្តូរជាដុំកំភួន ប្រយោជន៍ធ្វើឱ្យការគាំទ្រដល់ការអភិវឌ្ឍន៍សមត្ថភាពរឹតតែមានប្រសិទ្ធភាព ។

### ***យើងនឹងពង្រឹង និងបង្កើនការប្រើប្រាស់ឱ្យអស់ពីលទ្ធភាពនូវប្រព័ន្ធរបស់ប្រទេសកំពុងអភិវឌ្ឍន៍***

១៥- ការអភិវឌ្ឍន៍មួយប្រកបដោយជោគជ័យ គឺអាស្រ័យជាចម្បង លើសមត្ថភាពរបស់រដ្ឋាភិបាលមួយ ដែលអាចអនុវត្តនូវគោលនយោបាយ និងគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដោយប្រើប្រាស់នូវស្ថាប័ន និងប្រព័ន្ធរបស់ជាតិ ។ នៅក្នុងសេចក្តីថ្លែងការណ៍ទីក្រុងប៉ារីស ប្រទេសកំពុងអភិវឌ្ឍន៍ប្តេជ្ញាធ្វើការពង្រឹងនូវប្រព័ន្ធ និងស្ថាប័នជាតិ ដោយឡែកប្រទេស/ ស្ថាប័នផ្តល់ហិរញ្ញប្បទានបានប្តេជ្ញានឹងប្រើប្រាស់ប្រព័ន្ធ និងស្ថាប័នទាំងនោះឱ្យបានច្រើនបំផុត ។ ទោះបីយ៉ាងណាក៏ដោយ មានភស្តុតាងបង្ហាញថា ប្រទេសកំពុងអភិវឌ្ឍន៍ ក៏ដូចជាប្រទេស/ ស្ថាប័នផ្តល់ហិរញ្ញប្បទាន នឹងមិនអាចសម្រេចបានតាមការប្តេជ្ញារបស់ខ្លួនបានទេ ។ វឌ្ឍនភាពក្នុងការធ្វើឱ្យប្រសើរឡើងនូវគុណភាពនៃប្រព័ន្ធរបស់ជាតិ មានលក្ខណៈខុសៗគ្នានៅតាមប្រទេសនិមួយៗ ។ បើទោះបីជាមានប្រព័ន្ធរបស់ជាតិដែលមានគុណសម្បត្តិត្រឹមត្រូវក៏ដោយ ប្រទេស/ ស្ថាប័នផ្តល់ហិរញ្ញប្បទានកម្រនឹងប្រើប្រាស់ប្រព័ន្ធទាំងនោះណាស់ បើទោះបីជាគេបានទទួលស្គាល់ថា ការប្រើប្រាស់ប្រព័ន្ធរបស់ជាតិនឹងជម្រុញឱ្យមានការអភិវឌ្ឍន៍ ។ ដើម្បីពង្រឹង និងបង្កើនការប្រើប្រាស់ប្រព័ន្ធរបស់ជាតិក្នុងប្រទេស យើងនឹងអនុវត្តសកម្មភាពដូចតទៅ ÷

ក- ប្រទេស/ ស្ថាប័នផ្តល់ហិរញ្ញប្បទានយល់ព្រមនឹងប្រើប្រាស់ប្រព័ន្ធរបស់ជាតិ ជាជម្រើសទីមួយ សម្រាប់កម្មវិធីទាំងឡាយដែលគ្រប់គ្រងដោយស្ថាប័នវិស័យសាធារណៈ ។

ខ- ប្រសិនបើប្រទេស/ ស្ថាប័នផ្តល់ហិរញ្ញប្បទានជ្រើសយកជម្រើសផ្សេង និងប្រើប្រាស់នូវយន្តការផ្តល់ហិរញ្ញប្បទានដែលនៅក្រៅប្រព័ន្ធរបស់ជាតិ ( ដោយរួមទាំងការប្រើប្រាស់អង្គភាពអនុវត្តគម្រោងដាច់ដោយឡែក) ពួកគេនឹងពន្យល់ដោយច្បាស់លាស់ពីហេតុផលដែលធ្វើឱ្យពួកគេមិនអាចប្រើប្រាស់ប្រព័ន្ធរបស់ជាតិបាន ព្រមទាំងធ្វើការពិនិត្យឡើងវិញជាទៀងទាត់នូវជំហររបស់ខ្លួនលើបញ្ហានេះ ។ ក្នុងករណីដែលការប្រើប្រាស់ប្រព័ន្ធរបស់ជាតិ

មិនអាចធ្វើទៅបាន ប្រទេស/ ស្ថាប័នផ្តល់ហិរញ្ញប្បទាននឹងរៀបចំឱ្យមាននូវវិធានការការពារបន្ថែម សំដៅជួយពង្រឹងជាជាងធ្វើអោយប្រព័ន្ធ និងនីតិវិធីរបស់ជាតិចុះខ្សោយ ។

គ- ប្រទេសកំពុងអភិវឌ្ឍន៍ និងប្រទេស/ ស្ថាប័នផ្តល់ហិរញ្ញប្បទាន នឹងវាយតម្លៃរួមគ្នាលើគុណភាពនៃប្រព័ន្ធរបស់ជាតិ ដោយប្រើប្រាស់យន្តការវាយតម្លៃរបស់ជាតិ និងឧបករណ៍វាយតម្លៃដែលបានព្រមឯកភាពគ្នា ។ ប្រសិនបើប្រព័ន្ធរបស់ជាតិតម្រូវឱ្យមានការពង្រឹងបន្ថែម ប្រទេសកំពុងអភិវឌ្ឍន៍នឹងដឹកនាំការរៀបចំកម្មវិធីកែទម្រង់ និងកំណត់អាទិភាព ។ ប្រទេស/ ស្ថាប័នផ្តល់ហិរញ្ញប្បទាននឹងគាំទ្រកម្មវិធីកែទម្រង់នេះ ព្រមជាមួយការអភិវឌ្ឍន៍សមត្ថភាព ។

ឃ- ប្រទេស/ ស្ថាប័នផ្តល់ហិរញ្ញប្បទាននឹងចាប់ផ្តើមរៀបចំជាបន្ទាន់ ព្រមទាំងធ្វើការផ្សព្វផ្សាយ នូវផែនការមួយដែលបង្ហាញយ៉ាងច្បាស់ពីជំហានដើម្បីអនុវត្តការប្តេជ្ញាចិត្តដែលបានធ្វើនៅក្នុងសេចក្តីថ្លែងការណ៍ទីក្រុងប៉ារីសស្តីពីការប្រើប្រាស់ប្រព័ន្ធរបស់ជាតិសម្រាប់គ្រប់ទម្រង់នៃការផ្តល់ហិរញ្ញប្បទាន ។ ជាមួយនេះត្រូវផ្តល់ការណែនាំដល់បុគ្គលិកពីវិធីប្រើប្រាស់ប្រព័ន្ធទាំងនោះ ព្រមទាំងធានាឱ្យមានប្រព័ន្ធលើកទឹកចិត្តត្រឹមត្រូវដល់ការប្រើប្រាស់ប្រព័ន្ធរបស់ជាតិ ។ ប្រទេស/ ស្ថាប័នផ្តល់ហិរញ្ញប្បទាននឹងចាត់ទុកការរៀបចំ និងអនុម័តផែនការខាងលើជាកិច្ចការបន្ទាន់ ។

ង- ប្រទេស/ ស្ថាប័នផ្តល់ហិរញ្ញប្បទាន ធ្វើការអះអាងសាជាថ្មី នូវការប្តេជ្ញាចិត្តដែលមាននៅក្នុងសេចក្តីថ្លែងការណ៍ទីក្រុងប៉ារីស នឹងផ្តល់ហិរញ្ញប្បទានដោយប្រើប្រាស់នូវអភិក្រមគ្រប់គ្រងតាមកម្មវិធី ឱ្យបាន ៦៦% នៃហិរញ្ញប្បទានសរុប ។ លើសពីនេះទៀត ប្រទេស/ ស្ថាប័នផ្តល់ហិរញ្ញប្បទាននឹងខិតខំប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរបស់ជាតិឱ្យបានលើសពី ៥០% សម្រាប់ហិរញ្ញប្បទានដែលផ្តល់ពីរដ្ឋាភិបាលដល់រដ្ឋាភិបាល ដោយរួមទាំងបង្កើនការប្រើប្រាស់អភិក្រមគ្រប់គ្រងតាមកម្មវិធី ។

## កសាងភាពជាដៃគូមួយដែលមានប្រសិទ្ធភាព និងមានការចូលរួមដើម្បីអភិវឌ្ឍន៍

១៦- ហិរញ្ញប្បទានសហប្រតិបត្តិការគឺការកសាងភាពជាដៃគូសម្រាប់ការអភិវឌ្ឍន៍ ។ ប្រសិទ្ធភាពនៃភាពជាដៃគូនេះអាស្រ័យនឹងការដាក់បញ្ចូល និងចែករំលែកជាមួយគ្នា នូវថាមពល ជំនាញ និងបទពិសោធន៍របស់តួអង្គទាំងឡាយ ឱ្យបានពេញលេញ រវាងប្រទេស/ ស្ថាប័នផ្តល់ហិរញ្ញប្បទានទ្វេភាគី ពហុភាគី និងមូលនិធិពិភពលោក អង្គការសង្គមស៊ីវិល និងវិស័យឯកជន ។ ជាការគាំទ្រដល់កិច្ចប្រឹងប្រែងរបស់ ប្រទេសកំពុងអភិវឌ្ឍន៍ក្នុងការកសាងភាពជាដៃគូមួយដែលស្ថិតស្ថេរសម្រាប់អនាគត យើងប្តេជ្ញានឹងធានាឱ្យមានការចូលរួមទូលំទូលាយមួយសម្រាប់ដៃគូដែលពាក់ព័ន្ធទាំងអស់ ។

### *យើងនឹងកាត់បន្ថយហិរញ្ញប្បទានបែកខ្ញែក*

១៧- ប្រសិទ្ធិភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការនឹងត្រូវកាត់បន្ថយ នៅពេលដែលគេបង្កើតកម្មវិធីដូចៗគ្នាជាច្រើនជាពិសេសនៅក្នុងប្រទេស និងនៅតាមវិស័យ ។ យើងនឹងកាត់បន្ថយការបែកខ្ញែកនៃហិរញ្ញប្បទានសហប្រតិបត្តិការ ដោយជម្រុញឱ្យកិច្ចប្រឹងប្រែងរបស់ប្រទេស/ ស្ថាប័នផ្តល់ហិរញ្ញប្បទាន មានការបំពេញឱ្យគ្នាទៅវិញទៅមក បំណែងចែកភារកិច្ចក្នុងចំណោមប្រទេស/ ស្ថាប័នផ្តល់ហិរញ្ញប្បទាន ដោយរួមទាំងការធ្វើឱ្យប្រសើរឡើងនូវការបម្រុងធនធាននៅតាមវិស័យ នៅតាមប្រទេស និងសម្រាប់ប្រទេសទាំងអស់ ។ ក្នុងគោលដៅនេះ ÷

ក- ប្រទេសកំពុងអភិវឌ្ឍន៍នឹងកំណត់នូវតួនាទីដ៏ប្រសើរបំផុត នៃប្រទេស/ ស្ថាប័នផ្តល់ហិរញ្ញប្បទានក្នុងការគាំទ្រកិច្ចខិតខំប្រឹងប្រែងដើម្បីអភិវឌ្ឍន៍ជាតិ សម្រាប់កម្រិតតំបន់ និងវិស័យ ។ ប្រទេស/ ស្ថាប័នផ្តល់ហិរញ្ញប្បទាននឹងគោរពតាមអាទិភាពរបស់ប្រទេសកំពុងអភិវឌ្ឍន៍ ដោយធានាថាបំណែងចែកភារកិច្ចរវាងប្រទេស/ ស្ថាប័នផ្តល់ហិរញ្ញប្បទាននឹងមិនបន្ថយនូវកម្រិតហិរញ្ញប្បទានសម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍នោះទេ ។

ខ- ប្រទេស/ ស្ថាប័នផ្តល់ហិរញ្ញប្បទាន និងប្រទេសកំពុងអភិវឌ្ឍន៍ នឹងសហការជាមួយក្រុមការងារស្តីពីប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការ (Working Party on Aid Effectiveness) ដើម្បីបញ្ចប់ការរៀបចំឯកសារកិច្ចប្រតិបត្តិល្អស្តីពីបំណែងចែកភារកិច្ច ។ ក្នុងគោលដៅនេះ ពួកគេនឹងរៀបចំផែនការល្អិតល្អន់មួយ ដើម្បីធានាឱ្យមានការសហការ និងការសម្របសម្រួលយ៉ាងពេញលេញ ។ យើងនឹងវាយតម្លៃពីវឌ្ឍនភាពក្នុងការងារនេះចាប់ពីឆ្នាំ ២០០៩ ។

គ- យើងនឹងចាប់ផ្តើមដំណើរការនៃការពិភាក្សាអំពីបំណែងចែងភារកិច្ចជាលក្ខណៈអន្តរជាតិ សម្រាប់ប្រទេសទាំងអស់ នៅខែមិថុនាឆ្នាំ ២០០៩ ។

ឃ- យើងនឹងធ្វើសហការដើម្បីដោះស្រាយបញ្ហារបស់ប្រទេសដែលទទួលហិរញ្ញប្បទានសហប្រតិបត្តិការមិនគ្រប់គ្រាន់ ។

## ***យើងនឹងបង្កើនគុណតម្លៃនៃហិរញ្ញប្បទានសហប្រតិបត្តិការ***

១៨- ចាប់ពីការអនុម័តសេចក្តីថ្លែងការណ៍ទីក្រុងប៉ារីស ក្នុងឆ្នាំ ២០០៥ មក ប្រទេស/ ស្ថាប័នផ្តល់ហិរញ្ញប្បទានដែលជាសមាជិករបស់គណៈកម្មាធិការហិរញ្ញប្បទានអភិវឌ្ឍន៍ នៃអង្គការដើម្បីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍ សម្រេចបានវឌ្ឍនភាពក្នុងការកាត់បន្ថយហិរញ្ញប្បទានហប្រតិបត្តិការដោយភ្ជាប់លក្ខខ័ណ្ឌ ។ មានប្រទេស/ ស្ថាប័នផ្តល់ហិរញ្ញប្បទានមួយចំនួន បានផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការដោយគ្មានលក្ខខ័ណ្ឌទាំងស្រុង និងក្នុងស្មារតីនេះ យើងលើកទឹកចិត្តឱ្យប្រទេស/ ស្ថាប័នផ្តល់ហិរញ្ញប្បទានផ្សេងទៀតអនុវត្តតាមដូចនេះដែរ ។ យើងនឹងបន្ត និងពន្លឿនការប្រឹងប្រែងនេះ ដោយអនុវត្តសកម្មភាពដូចខាងក្រោមនេះ ÷

ក- ប្រទេស/ ស្ថាប័នផ្តល់ហិរញ្ញប្បទាន ដែលជាសមាជិករបស់គណៈកម្មាធិការហិរញ្ញប្បទានសហប្រតិបត្តិការ នៃអង្គការដើម្បីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍ នឹងពង្រីកវិសាលភាពគ្របដណ្តប់នៃអនុសាសន៍របស់គណៈកម្មាធិការហិរញ្ញប្បទានសហប្រតិបត្តិការស្តីពីហិរញ្ញប្បទានដោយគ្មានភ្ជាប់លក្ខខ័ណ្ឌ ឆ្នាំ២០០១ (DAC Recommendation on Untying Aid) ឱ្យដល់ប្រទេសក្រីក្រដែលជំពាក់បំណុលច្រើន និងដែលមិនស្ថិតក្នុងក្រុមប្រទេសដែលមានការអភិវឌ្ឍន៍តិចតួចបំផុត (Non-LDC HIPCs) និងកែលំអការរាយការណ៍អំពីការអនុវត្តន៍នូវអនុសាសន៍នេះផងដែរ ។

ខ- ប្រទេស/ ស្ថាប័នផ្តល់ហិរញ្ញប្បទាននឹងរៀបចំផែនការល្អិតល្អន់រៀងៗខ្លួន ដើម្បីឈានទៅកាត់បន្ថយហិរញ្ញប្បទានមានលក្ខខ័ណ្ឌ ឱ្យបានជាអតិបរមា ។

គ- ប្រទេស/ ស្ថាប័នផ្តល់ហិរញាប្បទាននឹងជម្រុញឱ្យមានការប្រើប្រាស់លទ្ធកម្មក្នុងស្រុក និងក្នុងតំបន់ ដោយធានាថានីតិវិធីលទ្ធកម្មទាំងនេះមានតម្លាភាព និងផ្តល់ឱកាសប្រកួតប្រជែងដល់ក្រុមហ៊ុនក្នុងស្រុក និងក្នុងតំបន់ ។ យើងជួយលើកកំពស់សមត្ថភាពរបស់ក្រុមហ៊ុនក្នុងស្រុក ឈរលើកិច្ចប្រតិបត្តិល្អៗដែលមាន ដើម្បីអោយពួកគេអាចប្រកួតប្រជែងដោយជោគជ័យនៅក្នុងដំណើរការលទ្ធកម្ម ។

ឃ- យើងនឹងគោរពតាមកិច្ចព្រមព្រាងអន្តរជាតិរបស់យើងស្តីពីការទទួលខុសត្រូវសាជីវកម្មនៅក្នុងសង្គម ។

## ***យើងស្វាគមន៍ និងរួមសហការជាមួយតួអង្គអភិវឌ្ឍន៍***

១៩- វិភាគទានរបស់ដៃគូអភិវឌ្ឍន៍ទាំងអស់កាន់តែមានប្រសិទ្ធិភាព នៅពេលដែលប្រទេស កំពុងអភិវឌ្ឍន៍អាចមានលទ្ធភាពគ្រប់គ្រង និងសម្របសម្រួលសកម្មភាពរបស់ពួកគេ ។ យើងសូមស្វាគមន៍តួនាទីរបស់តួអង្គថ្មីៗ និងកែលំអការសហការរវាងដៃគូទាំងអស់ ដោយវិធានការដូចខាងក្រោម ÷

ក- យើងលើកទឹកចិត្តឱ្យដៃគូអភិវឌ្ឍន៍ទាំងអស់ រួមទាំងដៃគូដែលចូលរួមក្នុងកិច្ចសហប្រតិបត្តិការត្បូង-ត្បូង ឱ្យយកគោលការណ៍សេចក្តីថ្លែងការណ៍ទីក្រុងប៉ារីសជាមូលដ្ឋានសម្រាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ ។

ខ- យើងសូមទទួលស្គាល់វិភាគទានរបស់ដៃគូអភិវឌ្ឍន៍ទាំងអស់ ពិសេសតួនាទីនៃប្រទេសដែលមានចំណូលមធ្យម ក្នុងនាមជាអ្នកផ្តល់ និងអ្នកទទួលផលពីហិរញ្ញប្បទានសហប្រតិបត្តិការ ។ យើងទទួលស្គាល់សារៈសំខាន់ និងលក្ខណៈពិសេសរបស់កិច្ចសហប្រតិបត្តិការត្បូង- ត្បូង និងអាចដកស្រង់យកបទពិសោធន៍ពីប្រទេសកំពុងអភិវឌ្ឍន៍ ។ យើងជំរុញឱ្យមានកិច្ចសហប្រតិបត្តិការត្រីភាគីច្រើនថែមទៀត ។

គ- មូលនិធិ និងកម្មវិធីពិភពលោក បានចូលរួមចំណែកយ៉ាងសំខាន់ក្នុងការអភិវឌ្ឍន៍ ។ ការគាំទ្រដែលផ្តល់មានប្រសិទ្ធភាពខ្ពស់បំផុត ដោយរួមជាមួយកិច្ចប្រឹងប្រែងផ្សេងៗទៀត ដើម្បីកែលំអបរិស្ថាន គោលនយោបាយ និងពង្រឹងសមត្ថភាពស្ថាប័ននៅក្នុងវិស័យដែលពួកគេមានប្រតិបត្តិការ ។ យើងសូមអំពាវនាវដល់មូលនិធិពិភពលោកទាំងអស់ ឱ្យផ្តល់ការគាំទ្រដល់ភាពជាម្ចាស់របស់ប្រទេស ធ្វើការតម្រឹម និងសុខដុមនីយកម្មឱ្យបានកាន់តែសកម្ម និងប្រើប្រាស់ឱ្យបានកាន់តែច្រើននូវយន្តការនៃការទទួលខុសត្រូវទ្វេទិស ស្របពេលជាមួយគ្នា ផ្តោតលើលទ្ធផល ។ ទន្ទឹមពេលដែលបញ្ហាប្រឈមសកលថ្មីៗបានលេចរូបរាងឡើង ប្រទេស/ ស្ថាប័នផ្តល់ហិរញ្ញប្បទាននឹងធានាថាយន្តការផ្តល់ហិរញ្ញប្បទានដែលមានស្រាប់នឹងត្រូវបានយកមកប្រើ និងពង្រឹងសមត្ថភាពប្រសិនបើចាំបាច់ មុននឹងបង្កើតយន្តការដោយឡែកថ្មីដែលអាចបណ្តាលឱ្យការផ្តល់ហិរញ្ញប្បទាន មានការបែកខ្ញែកបន្ថែមទៀត និងបង្កឱ្យមានភាពស្មុគ្រស្មាញដល់ការសម្របសម្រួលសកម្មភាពនៅក្នុងប្រទេសនិមួយៗ ។ យើងលើកទឹកចិត្តឱ្យប្រទេសកំពុងអភិវឌ្ឍន៍ កៀគរ គ្រប់គ្រង និងវាយតម្លៃគំនិតផ្តួចផ្តើមនៃកិច្ចសហប្រតិបត្តិការជាអន្តរជាតិ ដើម្បីជាប្រយោជន៍ដល់ប្រទេសកំពុងអភិវឌ្ឍន៍ដទៃទៀត ។

ឃ- កិច្ចសហប្រតិបត្តិការត្បូង- ត្បូង គឺឈរលើគោលការណ៍មិនជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងរវាងប្រទេស និងប្រទេស សមភាពរវាងភាគី និងការគោរពនូវឯករាជ្យភាព អធិបតេយ្យភាពដែនដី ភាពចម្រុះវប្បធម៌ អត្តសញ្ញាណ និងទំនៀមទំលាប់មូលដ្ឋាន ។ កិច្ចសហការត្បូង- ត្បូងមានតួនាទីសំខាន់នៅក្នុងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ជាអន្តរជាតិ ហើយផ្តល់អត្ថប្រយោជន៍បន្ថែមដល់កិច្ចសហប្រតិបត្តិការជើង- ត្បូង ។

### ***យើងនឹងពង្រឹងកិច្ចសហការជាមួយអង្គការសង្គមស៊ីវិល***

២០- យើងនឹងពង្រឹងកិច្ចសហការរបស់យើងជាមួយអង្គការសង្គមស៊ីវិល ដែលជាដៃគូអភិវឌ្ឍន៍មួយដ៏សំខាន់ បំពេញបន្ថែមដល់កិច្ចប្រឹងប្រែងរបស់រដ្ឋាភិបាល និងវិស័យឯកជន ។ យើងយល់ស្របថា វិភាគទានរបស់អង្គការសង្គមស៊ីវិល គួរតែត្រូវប្រែក្លាយឱ្យជាសក្តានុពលពេញលេញសម្រាប់ការអភិវឌ្ឍន៍ ។ ដូចនេះ ÷

ក- យើងស្នើឱ្យអង្គការសង្គមស៊ីវិល ធ្វើការឆ្លុះបញ្ចាំង ផ្អែកលើទស្សនៈវិស័យរបស់អង្គការសង្គមស៊ីវិល ការអនុវត្តន៍គោលការណ៍នៃសេចក្តីថ្លែងការណ៍ទីក្រុងប៉ារីសស្តីពីប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការ ។

ខ- យើងស្វាគមន៍គំនិតផ្តួចផ្តើមរបស់អង្គការសង្គមស៊ីវិលឱ្យមានការចូលរួមចំណែកជាមួយពួកគេនៅក្នុងដំណើរការពហុដៃគូមួយដែលដឹកនាំដោយអង្គការសង្គមស៊ីវិល ដើម្បីជម្រុញប្រសិទ្ធភាពរបស់អង្គការសង្គមស៊ីវិលក្នុងការអភិវឌ្ឍន៍ ។ ជាផ្នែកមួយនៃដំណើរការនោះ យើងនឹង (១) ធ្វើឱ្យប្រសើរឡើងនូវការសម្របសម្រួលរវាងអង្គការសង្គមស៊ីវិល ជាមួយកម្មវិធីរបស់រដ្ឋាភិបាល (២) ជម្រុញឱ្យមានការទទួលខុសត្រូវរបស់អង្គការសង្គមស៊ីវិលលើលទ្ធផល និង (៣) កែលំអការផ្តល់ពត៌មានអំពីសកម្មភាពរបស់អង្គការសង្គមស៊ីវិល ។

គ- យើងនឹងសហការជាមួយអង្គការសង្គមស៊ីវិល ដើម្បីផ្តល់ឱកាសឱ្យមានការចូលរួមរបស់ពួកគេ នៅក្នុងការអភិវឌ្ឍន៍ ។

***យើងនឹងមានភាពទន់ភ្លន់អំពីគោលនយោបាយហិរញ្ញប្បទានចំពោះប្រទេសស្ថិតក្នុងស្ថានភាពផុយស្រួយ***

២១- នៅក្នុងសេចក្តីថ្លែងការណ៍ទីក្រុងប៉ារីស យើងយល់ស្របថា គោលការណ៍ស្តីពីប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការ នឹងត្រូវបានប្រកាន់ខ្ជាប់ផងដែរចំពោះប្រទេសដែលស្ថិតក្នុងស្ថានភាពផុយស្រួយ រួមទាំងប្រទេសដែលទើបងើបពីជម្លោះ ។ យើងបានឯកភាពផងដែរថា គោលការណ៍ទាំងនេះត្រូវមានភាពទន់ភ្លន់ទៅនឹងស្ថានភាពដែលសមត្ថភាព និងភាពជាម្ចាស់របស់ប្រទេសទាំងនោះ នៅមានភាពទន់ខ្សោយនៅឡើយ ។ ចាប់ពីពេលនោះមក យើងបានយល់ស្របលើគោលការណ៍សម្រាប់ការចូលរួមជាអន្តរជាតិក្នុងប្រទេសដែលមានភាពផុយស្រួយ (Principles for Good International Engagement in Fragile States) ។ ដើម្បីលើកកំពស់ប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការបន្ថែមទៀតនៅក្នុងស្ថានភាពដូចនេះ យើងនឹងអនុវត្តដូចខាងក្រោម ÷

ក- ប្រទេស/ ស្ថាប័នផ្តល់ហិរញ្ញប្បទាន នឹងរួមគ្នាធ្វើការវាយតម្លៃអំពីអភិបាលកិច្ច និងសមត្ថភាព និងពិនិត្យពីឫសគល់នៃទំនាស់ ភាពផុយស្រួយ និងអសន្តិសុខ ដោយសហការឱ្យអស់លទ្ធភាព ជាមួយអាជ្ញាធរមានសមត្ថកិច្ចរបស់ប្រទេសកំពុងអភិវឌ្ឍន៍ និងដៃគូពាក់ព័ន្ធផ្សេងទៀត ។

ខ- នៅតាមប្រទេសនីមួយៗ ប្រទេស/ ស្ថាប័នផ្តល់ហិរញ្ញប្បទាន រួមជាមួយប្រទេសកំពុងអភិវឌ្ឍន៍ នឹងធ្វើការឯកភាពជាមួយគ្នា លើគោលដៅជាក់ស្តែងរួមមួយចំនួនសម្រាប់ការកសាងសន្តិភាព និងកសាងស្ថាប័នរដ្ឋសម្រាប់ជាដំណោះស្រាយអំពីឫសគល់នៃជម្លោះ និងភាពផុយស្រួយ ក៏ដូចជាធានាឱ្យមានការចូលរួម និងការពារដល់ស្ត្រី ។ ដំណើរការនេះនឹងធ្វើតាមរយៈការពិភាក្សាជាអន្តរជាតិរវាងប្រទេសជាដៃគូ និងប្រទេស/ ស្ថាប័នផ្តល់ហិរញ្ញប្បទានអំពីគោលដៅរួមទាំងនេះ ដែលជាបុរេលក្ខខ័ណ្ឌសម្រាប់ការអភិវឌ្ឍន៍ ។

គ- ប្រទេស/ ស្ថាប័នផ្តល់ហិរញ្ញប្បទាននឹងផ្តល់ការគាំទ្រការអភិវឌ្ឍន៍សមត្ថភាព ដែលឆ្លើយតបតាមតម្រូវការរបស់ប្រទេសកំពុងអភិវឌ្ឍន៍ មានភាពជាក់ស្តែង និងសម្របសម្រួល សម្រាប់ធានាឱ្យមានការបំពេញនូវមុខងារសំខាន់ៗរបស់រដ្ឋ និងដំណើរការឈានទៅមុខដោយនិរន្តរភាព ។ ពួកគេនឹងសហការជាមួយប្រទេសកំពុងអភិវឌ្ឍន៍ ក្នុងការដាក់ចេញនូវវិធានការបណ្តោះអាសន្ន តាមលំដាប់លំដោយ សម្រាប់ដំណើរការជាប់លាប់របស់ស្ថាបន័ ។

ឃ- ប្រទេស/ ស្ថាប័នផ្តល់ហិរញ្ញប្បទាននឹងប្រើប្រាស់ទម្រង់ការផ្តល់ហិរញ្ញប្បទាន ដែលមានភាពទន់ភ្លន់ ឆាប់រហ័ស និងសម្រាប់រយៈពេលវែង និងប្រើប្រាស់ទម្រង់ការហិរញ្ញប្បទានជាកញ្ចប់បើសមស្រប ដើម្បី (១) ផ្សាភ្ជាប់ដំណាក់កាលផ្សេងៗនៃការងារសង្គ្រោះមនុស្សធម៌ ការស្តារឡើងវិញ និងការអភិវឌ្ឍន៍សម្រាប់រយៈពេលវែង និង (២) គាំទ្រកិច្ចប្រឹងប្រែងធ្វើឱ្យមានស្ថេរភាព រួមទាំងការកសាងសន្តិភាពពេញលេញ និងការកសាងរដ្ឋដែលមានសមត្ថភាព ប្រកបដោយការទទួលខុសត្រូវ និងឆ្លើយតបនឹងតម្រូវការប្រជាជន ។ ដោយសហការជាមួយប្រទេសកំពុងអភិវឌ្ឍន៍ ប្រទេស/ ស្ថាប័នផ្តល់ហិរញ្ញប្បទាននឹងជម្រុញឱ្យមានភាពជាដៃគូជាមួយប្រព័ន្ធអង្គការសហប្រជាជាតិ ស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ និងប្រទេស/ ស្ថាប័នផ្តល់ហិរញ្ញប្បទានផ្សេងទៀត ។

ង- នៅតាមប្រទេសនីមួយៗ និងដោយឈរលើគោលការណ៍ស្ម័គ្រចិត្ត ប្រទេស/ ស្ថាប័នផ្តល់ហិរញ្ញប្បទាន និងប្រទេសកំពុងអភិវឌ្ឍន៍នឹងត្រួតពិនិត្យការអនុវត្តន៍គោលការណ៍ល្អៗសម្រាប់ការចូលរួមជាអន្តរជាតិនៅក្នុងប្រទេសដែលមានភាពផុយស្រួយ និងចែករំលែករបាយការណ៍វឌ្ឍនភាពទាំងនោះ ជាផ្នែកមួយនៃការអនុវត្តន៍សេចក្តីថ្លែងការណ៍ទីក្រុងប៉ារីស ។

## ផ្ដោតលើលទ្ធផល និងទទួលខុសត្រូវចំពោះលទ្ធផលនៃការអភិវឌ្ឍន៍

២២- កិច្ចប្រឹងប្រែងរួមរបស់យើងនឹងត្រូវបានវិនិច្ឆ័យ តាមរយៈការផ្លាស់ប្ដូរជីវភាពរស់នៅរបស់ប្រជាជនក្រីក្រ ។ យើងទទួលស្គាល់ភាពចាំបាច់នៃតម្លាភាព និងគណនេយ្យភាពក្នុងការប្រើប្រាស់ធនធានសម្រាប់ការអភិវឌ្ឍន៍ ទាំងធនធានក្នុងស្រុក និងធនធានដែលបានមកពីក្រៅប្រទេស ។

### *យើងនឹងផ្ដោតលើលទ្ធផលនៃការបំពេញកិច្ចការ*

២៣- យើងនឹងលើកកំពស់ការគ្រប់គ្រងដោយផ្ដោតលើលទ្ធផល ដោយសកម្មភាពដូចខាងក្រោម ÷

ក- ប្រទេសកំពុងអភិវឌ្ឍន៍និងពង្រឹងគុណភាពការរៀបចំគោលនយោបាយ ការអនុវត្តន៍ និងការវាយតម្លៃ តាមរយៈការកែលំអប្រព័ន្ធពត៌មាន រួមបញ្ចូលការបែងចែកទិន្នន័យតាមភេទ តាមតំបន់ និងសេដ្ឋកិច្ច- សង្គម ។

ខ- ប្រទេសកំពុងអភិវឌ្ឍន៍ និងប្រទេស/ ស្ថាប័នផ្ដល់ហិរញ្ញប្បទាន នឹងសហការបង្កើតឱ្យមានឧបករណ៍សម្រាប់គ្រប់គ្រងលទ្ធផល ដោយមានប្រសិទ្ធភាពថ្លៃ សម្រាប់ធ្វើការវាយតម្លៃផលប៉ះពាល់នៃគោលនយោបាយអភិវឌ្ឍន៍ និងធ្វើការកែសម្រួលប្រសិនបើចាំបាច់ ។ យើងនឹងសម្របសម្រួលឱ្យបានប្រសើរជាងមុន និងផ្សាភ្ជាប់នូវប្រភពពត៌មានផ្សេងៗគ្នា រួមទាំងប្រព័ន្ធស្ថិតិជាតិ ថវិកា ផែនការ ការត្រួតពិនិត្យ និងការវាយតម្លៃការអនុវត្តន៍គោលនយោបាយ ។

គ- ប្រទេស/ ស្ថាប័នផ្ដល់ហិរញ្ញប្បទាននឹងតម្រឹមយន្តការត្រួតពិនិត្យជាមួយប្រព័ន្ធពត៌មានរបស់ជាតិ ។ ពួកគេនឹងផ្ដល់ការគាំទ្រ និងផ្ដោតលើការពង្រឹង និងអភិវឌ្ឍសមត្ថភាពរបស់ប្រព័ន្ធស្ថិតិ និងពត៌មានរបស់ជាតិ ដោយរួមទាំងប្រព័ន្ធពត៌មានសម្រាប់គ្រប់គ្រងហិរញ្ញប្បទានសហប្រតិបត្តិការ ។

ឃ- យើងនឹងពង្រឹងប្រព័ន្ធលើកទឹកចិត្ត ក្នុងការលើកកំពស់ប្រសិទ្ធិភាពហិរញ្ញប្បទានសហប្រតិបត្តិការ ។ យើងនឹងពិនិត្យឡើងវិញ និងដោះស្រាយជាលក្ខណៈប្រព័ន្ធ នូវឧបសគ្គផ្លូវច្បាប់ ឬរដ្ឋបាលដែលរារាំងការអនុវត្តន៍នូវការប្ដេជ្ញាដែលយើងបានធ្វើជាអន្តរជាតិក្នុងការលើកកំពស់ប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការ ។ ប្រទេស/ ស្ថាប័នផ្ដល់ហិរញ្ញប្បទាននឹងយកចិត្តទុកដាក់បន្ថែមទៀត ក្នុងការធ្វើប្រតិភូកម្មអំណាចគ្រប់គ្រាន់ឱ្យដល់ការិយាល័យនៅតាមប្រទេស និងផ្លាស់ប្ដូររចនាសម្ព័ន្ធស្ថាប័ន និងប្រព័ន្ធលើកទឹកចិត្តមន្ត្រី ឱ្យស្របតាមគោលការណ៍ប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការ ។

### *យើងនឹងបង្កើនគណនេយ្យភាព និងតម្លាភាពអំពីលទ្ធផលចំពោះសាធារណជន*

២៤- តម្លាភាព និងគណនេយ្យភាពជាធាតុផ្សំដ៏សំខាន់ចំពោះលទ្ធផលនៃការអភិវឌ្ឍន៍ ។ វាស្ថិតនៅចំកណ្ដាលនៃសេចក្ដីថ្លែងការណ៍ទីក្រុងប៉ារីស ដែលក្នុងនោះ ប្រទេសកំពុងអភិវឌ្ឍន៍ និងប្រទេស/ ស្ថាប័នផ្ដល់ហិរញ្ញប្បទានយល់ស្របលើគណនេយ្យភាពទៅវិញទៅមក និងចំពោះប្រជាជន ។ យើងនឹងបន្តកិច្ចប្រឹងប្រែងនេះ ដោយអនុវត្តដូចតទៅ ÷

ក- យើងនឹងធ្វើឱ្យហិរញ្ញប្បទានសហប្រតិបត្តិការកាន់តែមានតម្លាភាព ។ ប្រទេសកំពុងអភិវឌ្ឍន៍នឹងជម្រុញឱ្យស្ថាប័នសភាអនុវត្តអំណាចក្នុងការតាមដាន ដោយបង្កើនតម្លាភាពក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ រួមមានការប្រកាសពីចំណូល ថវិកា ការចំណាយ លទ្ធកម្ម និងសវនកម្ម ។ ប្រទេស/ ស្ថាប័នផ្ដល់ហិរញ្ញប្បទាននឹងប្រកាសឱ្យដឹងជាសាធារណៈ នូវពត៌មានជាទៀងទាត់ លំអិត និងទាន់ពេលវេលា អំពីបរិមាណ ការបែងចែក និងពត៌មានស្ដីពីការប្រើប្រាស់ហិរញ្ញប្បទាននៅពេលមានពត៌មាន ដើម្បីអាចឱ្យប្រទេសកំពុងអភិវឌ្ឍន៍ មានលទ្ធភាពរៀបចំថវិកាអនុវត្តថវិកា និងធ្វើសវនកម្មមានភាពសុក្រឹត្យ ។

ខ- យើងនឹងបង្កើនកិច្ចប្រឹងប្រែងរបស់យើង ដូចដែលបានឯកភាពនៅក្នុងសេចក្តីថ្លែងការណ៍ទីក្រុងប៉ារីស ដើម្បីធានាថាយន្តការសម្រាប់ធ្វើការវាយតម្លៃរួមគ្នា ត្រូវបានបង្កើត និងដំណើរការនៅក្នុងឆ្នាំ ២០១០ សម្រាប់ប្រទេសទាំងអស់ដែលបានចុះហត្ថលេខាលើសេចក្តីថ្លែងការណ៍ទីក្រុងប៉ារីស ។ យន្តការវាយតម្លៃទាំងនេះនឹងប្រើប្រាស់ប្រព័ន្ធរាយការណ៍ពីលទ្ធផល និងពត៌មានរបស់ប្រទេសជាដៃគូ រួមផ្សំដោយទិន្នន័យរបស់ប្រទេស/ ស្ថាប័នផ្តល់ហិរញ្ញប្បទាន និងភស្តុតាងឯករាជ្យដែលអាចយកជាការបាន ។ យន្តការវាយតម្លៃទាំងនេះនឹងប្រើប្រាស់កិច្ចប្រតិបត្តិល្អៗ ថ្មីៗ ដែលទើបនឹងកកើត ដោយមានការចូលរួមពិនិត្យម៉ត់ចត់របស់ស្ថាប័នសភា និងរបស់ប្រជាពលរដ្ឋ ។ ការប្រើប្រាស់យន្តការនេះនឹងអាចឱ្យយើងកំណត់គណនេយ្យភាពរវាងគ្នាទៅវិញទៅមកលើលទ្ធផលដែលបានឯកភាព ស្របតាមគោលដៅអភិវឌ្ឍន៍ និងគោលនយោបាយហិរញ្ញប្បទានសហប្រតិបត្តិការ ។

គ- ជាការបំពេញបន្ថែមឱ្យយន្តការវាយតម្លៃរួមគ្នានៅកម្រិតប្រទេស និងជាការជម្រុញឱ្យការអនុវត្តន៍បានល្អប្រសើរ ប្រទេសកំពុងអភិវឌ្ឍន៍ និងប្រទេស/ ស្ថាប័នផ្តល់ហិរញ្ញប្បទាននឹងពិនិត្យរួមគ្នា និងពង្រឹងយន្តការអន្តរជាតិដែលមានស្រាប់សម្រាប់គណនេយ្យភាពទ្វេទិស ដោយរួមទាំងការតាមដានពិនិត្យ (Peer Review) ដែលធ្វើដោយមានការចូលរួមរបស់ប្រទេសកំពុងអភិវឌ្ឍន៍ ។ យើងនឹងពិនិត្យលើសំណើពង្រឹងយន្តការនេះនៅចុងឆ្នាំ ២០០៩ ។

ឃ- ប្រសិទ្ធភាពក្នុងការប្រើប្រាស់ហិរញ្ញប្បទានអភិវឌ្ឍន៍ តម្រូវឱ្យប្រទេស/ ស្ថាប័នផ្តល់ហិរញ្ញប្បទាន និងប្រទេសជាដៃគូ ខិតខំប្រឹងប្រែងប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ ។ ប្រទេស/ ស្ថាប័នផ្តល់ហិរញ្ញប្បទាន និងប្រទេសកំពុងអភិវឌ្ឍន៍ នឹងគោរពតាមគោលការណ៍នានាដែលបានឯកភាព រួមមានគោលការណ៍ដែលមាននៅក្នុងអនុសញ្ញាអង្គការសហប្រជាជាតិប្រឆាំងនឹងអំពើពុករលួយ ជាដើម ។ ប្រទេសកំពុងអភិវឌ្ឍន៍នឹងប្រយុទ្ធប្រឆាំងនឹងអំពីពុករលួយ តាមរយៈការលើកកំពស់ប្រព័ន្ធស៊ើបអង្កេត ការអនុវត្តន៍ច្បាប់ គណនេយ្យភាព និងតម្លាភាពក្នុងការប្រើប្រាស់ហិរញ្ញវត្ថុសាធារណៈ ។ ប្រទេស/ ស្ថាប័នផ្តល់ហិរញ្ញប្បទាននឹងអនុវត្តវិធានការនៅក្នុងប្រទេសរបស់ខ្លួន ជាការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយរបស់បុគ្គល ឬរបស់សាជីវកម្ម ដែលអាចឱ្យយើងតាមដាន បង្កក និងស្រាវជ្រាវត្រឡប់មកវិញនូវធនធានដែលបានមកពីអំពើពុករលួយ ។

### ***យើងនឹងបន្តកែប្រែចរិតលក្ខណៈនៃការដាក់លក្ខខ័ណ្ឌប្រយោជន៍ជម្រុញឱ្យមានភាពជាម្ចាស់***

២៥- ដើម្បីពង្រឹងភាពជាម្ចាស់របស់ប្រទេសជាដៃគូ និងធ្វើឱ្យប្រសើរនូវភាពអាចទស្សន៍ទាយជាមុនបាននូវលំហូរហិរញ្ញប្បទាន ប្រទេស/ ស្ថាប័នផ្តល់ហិរញ្ញប្បទានបានឯកភាពនៅក្នុងសេចក្តីថ្លែងការណ៍ទីក្រុងប៉ារីសថា នៅពេលសមស្របលក្ខខ័ណ្ឌ (Conditionality) សម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍ នឹងត្រូវទាញចេញពីគោលនយោបាយអភិវឌ្ឍន៍របស់ប្រទេសកំពុងអភិវឌ្ឍន៍ផ្ទាល់ ។ យើងអះអាងសាជាថ្មីការប្តេជ្ញារបស់យើងចំពោះគោលការណ៍នេះ និងបន្តធ្វើការកែប្រែចរិតលក្ខណៈនៃការដាក់លក្ខខ័ណ្ឌ ដោយសកម្មភាពដូចខាងក្រោម ÷

ក- ប្រទេស/ ស្ថាប័នផ្តល់ហិរញ្ញប្បទាន រួមជាមួយប្រទេសកំពុងអភិវឌ្ឍន៍ នឹងធ្វើការឯកភាពលើចង្កោមលក្ខខ័ណ្ឌមួយដោយផ្អែកលើយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ។ យើងនឹងរួមគ្នាវាយតម្លៃការអនុវត្តន៍ការប្តេជ្ញានេះ ដោយប្រទេស/ ស្ថាប័នផ្តល់ហិរញ្ញប្បទាន និងប្រទេសកំពុងអភិឌ្ឍន៍ ។

ខ- ចាប់ផ្តើមពីពេលនេះ ប្រទេស/ ស្ថាប័នផ្តល់ហិរញ្ញប្បទាន និងប្រទេសកំពុងអភិវឌ្ឍន៍ និងផ្សព្វផ្សាយជាសាធារណៈទៀងទាត់ នូវលក្ខខ័ណ្ឌទាំងអស់ដែលទាក់ទងនឹងការផ្តល់ហិរញ្ញប្បទាន ។

គ- ប្រទេសកំពុងអភិវឌ្ឍន៍ និងប្រទេស/ ស្ថាប័នផ្តល់ហិរញ្ញប្បទាន នឹងសហការគ្នាពិនិត្យឡើងវិញ កត់ត្រា និងផ្សព្វផ្សាយ នៅកម្រិតអន្តរជាតិ នូវកិច្ចប្រតិបត្តិល្អៗស្តីពីការដាក់លក្ខខ័ណ្ឌ ប្រយោជន៍ពង្រឹងភាពជាម្ចាស់របស់ប្រទេសជាដៃគូ

និងគោលការណ៍សេចក្តីថ្លែងការណ៍ទីក្រុងប៉ារីសដទៃទៀត ដោយបង្កើនការយកចិត្តទុកដាក់ពិសេស ការធ្វើសុខដុមនីយកម្មការដាក់លក្ខខ័ណ្ឌ និងដោយផ្អែកលើលទ្ធផល ។ យើងនឹងបើកចំហ ទទួលយកគំនិត និងការចូលរួមចំណែករបស់អង្គការសង្គមស៊ីវិល ។

### *យើងនឹងកែលំអភាពអាចទស្សន៍ទាយបាននៃហិរញ្ញប្បទានសម្រាប់រយៈពេលមធ្យម*

២៦- នៅក្នុងសេចក្តីថ្លែងការណ៍ទីក្រុងប៉ារីស យើងបានឯកភាពថាភាពអាចទស្សន៍ទាយបានកាន់តែច្រើនជាងមុននៃហិរញ្ញប្បទាន នឹងជួយឱ្យប្រទេសកំពុងអភិវឌ្ឍន៍អាចរៀបចំផែនការ និងគ្រប់គ្រងដោយប្រសិទ្ធភាព នូវកម្មវិធីអភិវឌ្ឍន៍សម្រាប់រយៈពេលខ្លី និងមធ្យម ។ ដោយចាត់ទុកជាអាទិភាព យើងនឹងអនុវត្តនូវសកម្មភាពខាងក្រោម ដើម្បីបង្កើនភាពអាចទស្សន៍ទាយបាននៃលំហូរហិរញ្ញប្បទាន ÷

ក- ប្រទេសកំពុងអភិវឌ្ឍន៍នឹងពង្រឹងដំណើរការរៀបចំផែនការថវិកា ក្នុងការគ្រប់គ្រងធនធានក្នុងស្រុក និងក្រៅប្រទេស និងកែលំអនូវទំនាក់ទំនងរវាងចំណាយ និងលទ្ធផលក្នុងរយៈពេលមធ្យម ។

ខ- ចាប់ផ្តើមពីពេលនេះ ប្រទេស/ ស្ថាប័នផ្តល់ហិរញ្ញប្បទាននឹងផ្តល់យ៉ាងពេញលេញ និងទាន់ពេលវេលា នូវពត៌មានអំពីការសន្យាហិរញ្ញប្បទានប្រចាំឆ្នាំ និងការផ្តល់ហិរញ្ញប្បទានជាក់ស្តែង សម្រាប់ឱ្យប្រទេសកំពុងអភិវឌ្ឍន៍អាចកត់ត្រាបានត្រឹមត្រូវនូវលំហូរហិរញ្ញប្បទានសហប្រតិបត្តិការទាំងអស់ ទៅក្នុងប្រព័ន្ធថវិកា និងគណនេយ្យរបស់ជាតិ ។

គ- ចាប់ផ្តើមពីពេលនេះ ប្រទេស/ ស្ថាប័នផ្តល់ហិរញ្ញប្បទាន នឹងផ្តល់ជាទៀងទាត់ និងទាន់ពេលវេលា ដល់ប្រទេសកំពុងអភិវឌ្ឍន៍ ពត៌មានស្តីពីហិរញ្ញប្បទានសម្រាប់ចំណាយរយៈពេលមធ្យមរំកិល ៣-៥ ឆ្នាំ និងផែនការសកម្មភាពនានា ដែលយ៉ាងហោចណាស់មានលក្ខណៈចង្អុលបង្ហាញអំពីការបម្រុងទុកធនធាន ដែលប្រទេសកំពុងអភិវឌ្ឍន៍អាចប្រើប្រាស់បានសម្រាប់បញ្ចូលទៅក្នុងផែនការ និងក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ចរយៈពេលមធ្យម ។ ប្រទេស/ ស្ថាប័នផ្តល់ហិរញ្ញប្បទាននឹងខិតខំដោះស្រាយបញ្ហាប្រឈមដែលបណ្តាលឱ្យខ្លួនមិនអាចផ្តល់ពត៌មានទាំងនេះបាន ។

ឃ- ប្រទេសកំពុងអភិវឌ្ឍន៍ និងប្រទេស/ ស្ថាប័នផ្តល់ហិរញ្ញប្បទាន នឹងសហការរួមគ្នាជាអន្តរជាតិ ក្នុងការកែលំអភាពអាចទស្សន៍ទាយបាននៃលំហូរហិរញ្ញប្បទាន សម្រាប់រយៈពេលមធ្យម ដោយបង្កើតឱ្យមានឧបករណ៍ចាំបាច់សម្រាប់វាស់ស្ទង់ផងដែរ ។

## **ជំហានបន្ទាប់**

២៧- ការកែទម្រង់ដែលយើងបានឯកភាពថ្ងៃនេះ នៅ ACCRA ទាមទារឱ្យមានការគាំទ្រផ្នែកនយោបាយកម្រិតខ្ពស់ ការដាក់សម្ពាធ និងសម្របសម្រួលការអនុវត្តន៍សកម្មភាព នៅកម្រិតជាសាកល តំបន់ និងនៅតាមប្រទេស ។ ដើម្បីសម្រេចជោគជ័យការកែទម្រង់ទាំងនេះ យើងអះអាងជាថ្មីម្តងទៀត នូវការប្តេជ្ញារបស់យើងលើគោលការណ៍ និងគោលដៅដែលបានកំណត់នៅក្នុងសេចក្តីថ្លែងការណ៍ទីក្រុងប៉ារីស និងបន្តកិច្ចប្រឹងប្រែងរបស់យើងក្នុងការវាយតម្លៃវឌ្ឍនភាពក្នុងការអនុវត្តន៍ការប្តេជ្ញាដែលយើងបានធ្វើ ។

២៨- ការប្តេជ្ញាដែលយើងបានធ្វើនៅថ្ងៃនេះ នឹងត្រូវកែសម្រួលឱ្យស្របតាមស្ថានការណ៍នៃប្រទេសនិមួយៗ រួមទាំងប្រទេសដែលមានចំណូលមធ្យម រដ្ឋតូចៗ និងរដ្ឋដែលស្ថិតក្នុងស្ថានភាពផុយស្រួយ ។ ក្នុងគោលដៅនេះ យើងលើកទឹកចិត្តឱ្យប្រទេសកំពុងអភិវឌ្ឍន៍ ដឹកនាំការរៀបចំផែនការសកម្មភាពមួយ ដោយមានការគាំទ្រយ៉ាងសកម្មពីប្រទេស/ ស្ថាប័នផ្តល់ហិរញ្ញប្បទាន ដែលបញ្ជាក់ច្បាស់ពីជំហាន និងដែលអាចតាមដានបាន សម្រាប់អនុវត្តសេចក្តីថ្លែងការណ៍ទីក្រុងប៉ារីស និងផែនការសកម្មភាពទីក្រុងអាក្រា ។

២៩- យើងឯកភាពថា នៅក្នុងឆ្នាំ ២០១០ ភាគីនិមួយៗគួរតែសម្រេចបានតាមការប្តេជ្ញារបស់ខ្លួន ក្នុងការលើកកំពស់ប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការ ដូចដែលយើងបានធ្វើនៅទីក្រុងប៉ារីស និងថ្ងៃនេះនៅ ACCRA និងលើសពីគោលដៅដែលយើងបានកំណត់ប្រសិនបើមានលទ្ធភាព ។ យើងយល់ស្របជាមួយការពិភាក្សា និងទទួលយកគំនិតដែលមានតម្លៃជាច្រើន ក៏ដូចជាការផ្តួចផ្តើមនានាដែលបានលើកឡើងនៅក្នុងវេទិកាកម្រិតខ្ពស់លើកនេះ ។ យើងឯកភាពផងដែរថា បញ្ហាប្រឈមដូចជាការប្រែប្រួលអាកាសធាតុ ការឡើងថ្លៃទំនិញ និងប្រេងឥន្ធនៈ គួសបញ្ជាក់ឱ្យឃើញច្បាស់នូវភាពចាំបាច់ក្នុងការអនុវត្តន៍គោលការណ៍ប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការ ។ ជាការឆ្លើយតបនឹងវិបត្តិម្ហូបអាហារ យើងនឹងបង្កើតឱ្យមាន និងអនុវត្តយ៉ាងសកម្មនូវភាពជាដៃគូជាសាកលក្នុងវិស័យកសិកម្ម និងម្ហូបអាហារ ដោយប្រសិទ្ធភាព និងទន់ភ្លន់ ។

៣០- យើងសូមស្នើឱ្យក្រុមការងារស្តីពីប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការ ឱ្យបន្តតាមដានវឌ្ឍនភាពការអនុវត្តន៍សេចក្តីថ្លែងការណ៍ទីក្រុងប៉ារីស និងផែនការសកម្មភាពអាក្រា និងរាយការណ៍ពីវឌ្ឍនភាពទាំងនេះ នៅឯវេទិកាកម្រិតខ្ពស់លើកទី ៤ ស្តីពីប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការ នៅឆ្នាំ ២០១១ ។ យើងទទួលស្គាល់នូវតម្រូវការការងារបន្ថែមដើម្បីកែលំអវិធីសាស្ត្រ និងសូចនាករកំណត់ពីវឌ្ឍនភាពក្នុងការលើកកំពស់ប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការ ។ នៅក្នុងឆ្នាំ ២០១១ យើងនឹងធ្វើការអង្កេតលើកទី ៣ ពីការអនុវត្តន៍តាមគោលដៅដែលបានកំណត់អនុវត្តឱ្យបានក្នុងឆ្នាំ ២០១០ ដូចដែលបានព្រមព្រៀងនៅឯទីក្រុងប៉ារីស កាលពីឆ្នាំ ២០០៥ ។ ជាការបន្តកិច្ចការនេះ យើងត្រូវរៀបចំដំណើរការស្ថាប័នសម្រាប់ធានាឱ្យមានភាពជាដៃគូមួយដែលមានសមភាពជាមួយប្រទេសកំពុងអភិវឌ្ឍន៍ និងមានការចូលរួមពីគ្រប់ដៃគូដែលពាក់ពន្ធ័ ។

៣១- យើងទទួលស្គាល់ថាការលើកកំពស់ប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការ គឺជាជ្រុងមិនអាចខ្វះបានមួយនៃរបៀបវារៈទូលំទូលាយស្តីពីហិរញ្ញប្បទានសម្រាប់ការអភិវឌ្ឍន៍ ។ ដើម្បីសម្រេចបាននូវលទ្ធផលអភិវឌ្ឍន៍ និងគោលដៅអភិវឌ្ឍន៍សហសវត្សរ៍ យើងត្រូវតែអនុវត្តឱ្យបាននូវការប្តេជ្ញារបស់យើងទៅលើគុណភាព និងបរិមាណនៃហិរញ្ញប្បទានសហប្រតិបត្តិការ ។ យើងសូមស្នើឱ្យអគ្គលេខាធិការអង្គការសហប្រជាជាតិ ពាំនាំយកសេចក្តីថ្លែងការណ៍នៃវេទិកាកម្រិតខ្ពស់លើកទី ៣ នេះ ទៅប្រកាសផ្សព្វផ្សាយនៅឯវេទិកាកម្រិតខ្ពស់ស្តីពីគោលដៅអភិវឌ្ឍន៍សហសវត្សរ៍ ដែលនឹងប្រារព្ធនៅទីក្រុង New York នាចំណាច់ខែនេះ និងទៅកាន់កិច្ចប្រជុំត្រួតពិនិត្យស្តីពីហិរញ្ញប្បទានសម្រាប់ការអភិវឌ្ឍន៍ នៅទីក្រុង Doha ក្នុងខែវិច្ឆិកា ឆ្នាំ ២០០៨ ។ យើងស្វាគមន៍ការរួមចំណែករបស់វេទិកាសម្រាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍របស់ក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គម (ECOSOC Development Cooperation Forum) ទៅក្នុងការពិភាក្សា និងគណនេយ្យភាពជាអន្តរជាតិស្តីពីហិរញ្ញប្បទានសហប្រតិបត្តិការ ។ យើងអំពាវនាវដល់ប្រព័ន្ធអង្គការសហប្រជាជាតិ ឱ្យផ្តល់ការគាំទ្រការអភិវឌ្ឍន៍សមត្ថភាពបន្ថែមទៀត ដល់ប្រទេសកំពុងអភិវឌ្ឍន៍ សម្រាប់ការគ្រប់គ្រងយ៉ាងមានប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការ ។

៣២- ថ្ងៃនេះ ជាងពេលណាៗទាំងអស់ យើងបានប្តេជ្ញានឹងសហការគ្នា ដើម្បីជួយប្រទេសជុំវិញពិភពលោក កសាងនូវអនាគតដ៏ជោគជ័យមួយដែលយើងទាំងអស់គ្នាចង់ឃើញ ជាអនាគតដែលផ្អែកលើការប្តេជ្ញារួមគ្នា ដើម្បីជំនះលើភាពក្រីក្រ និងជាអនាគតមួយដែលប្រទេសទាំងអស់នឹងមិនពឹងផ្អែកលើហិរញ្ញប្បទានសហប្រតិបត្តិការទៀតឡើយ ។